# ព្រះរាជក្រម

នស/រកម/០១០៦/០០៥

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារទី ៩ ស្តីពីទំនិញគ្រោះថ្នាក់ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០០៥ នាសម័យប្រជុំរដ្ឋសភាលើកទី ៣ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គ លើកទី ១០ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមលើពិធីសារទី ៩ ស្តីពីទំនិញគ្រោះថ្នាក់

**មាត្រា ១.-**

អនុម័តយល់ព្រមលើពិធីសារទី ៩ ស្តីពីទំនិញគ្រោះថ្នាក់ ដែលធ្វើនៅទីក្រុងហ្សាការតា ប្រទេសឥណ្ឌូនេស៊ី នាថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០០២ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តពិធីសារនេះ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១៨ ខែមករា ឆ្នាំ ២០០៦

៣ាល.០៦០១.០២៣ **ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

**ហត្ថលេខា**

**ស៊ុន ចាន់ថុល**

លេខ: ៣៦ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែមករា ឆ្នាំ២០០៦

**អគ្គលេខាធិការរងរដ្ឋាភិបាល**

**សាឌី តាន់**

# ពិធីសារទី ៩

# ស្តីពី

# ទំនិញគ្រោះថ្នាក់

# DANGEROUSE GOODS

# ពិធីសារទី ៩
## ទំនិញគ្រោះថ្នាក់

# PROTOCOL 9
## DANGEROUS GOODS

រដ្ឋាភិបាលរបស់ប្រទេស ប្រ៊ុយណេ ដារូសសាឡាម, ព្រះរាជាណាចក្រកម្ពុជា, សាធារណរដ្ឋឥណ្ឌូនេស៊ី, សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ, ម៉ាឡេស៊ី, សហភាពមីយ៉ាន់ម៉ា, សាធារណរដ្ឋហ្វីលីពីន, សាធារណរដ្ឋសិង្ហបុរី, ព្រះរាជាណាចក្រថៃឡង់ដ៏ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ដែលជាប្រទេសសមាជិក នៃសមាគមន៏ប្រជាជាតិអាស៊ី ភាគអគ្នេយ៏ ( ហៅកាត់ថាភាគីចុះកិច្ចសន្យា ) ។

**រំលឹកឡើងវិញ** នូវកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន ស្តីពីការសំរបសំរួលទំនិញឆ្លងកាត់ ដែលបានចុះហត្ថលេខា នៅថ្ងៃទី ១៦ ធ្នូ ១៩៩៨ នៅទីក្រុងហាណូយប្រទេសវៀតណាម ( ហៅកាត់ថាកិច្ចព្រមព្រៀង ) ។

**ទទួលស្គាល់ថា** មាត្រា ២០ និង ២៥ ដែលចែងពីការសំរេចលើការអនុវត្តន៏ពិធីសារផ្សេងៗ នឹងបង្កើតឡើងទៅជាផ្នែករួមបញ្ចូលគ្នានៃកិច្ចព្រមព្រៀង ។

**នៅពេលនេះ, ព្រោះហេតុនេះ, ភាគីចុះកិច្ចសន្យាទាំងឡាយបានឯកភាពដូចតទៅ :**

# មាត្រាទី ១
## និយមន័យ

**សំរាប់គោលបំណងនៃកិច្ចព្រមព្រៀងនេះ :**

ក- "ទំនិញគ្រោះថ្នាក់" "មធ្យោបាយដឹកជញ្ជូន" និង "ការដឹកជញ្ជូនឆ្លងកាត់" ត្រូវមាននិយមន័យដូចដែលបានកំណត់អោយក្នុងកិច្ចព្រមព្រៀង ។

ខ- " និយ័តកម្មជាគំរូរបស់អង្គការសហប្រជាជាតិ " មានន័យថា ជាអនុសាសាន៏ អង្គការសហប្រជាជាតិ ស្តីពីការដឹកជញ្ជូនទំនិញគ្រោះថ្នាក់ ឬជានិយ័តកម្មគំរូម៉ូដែល ។

គ- " ADR " មានន័យថា កិច្ចព្រមព្រៀងអឺរ៉ុបពាក់ព័ន្ធដល់ការដឹកជញ្ជូនទំនិញគ្រោះថ្នាក់ជាអន្តរជាតិតាមផ្លូវថ្នល់

ឃ- " ការកែសំរួលឡើងវិញ ADR " មានន័យថា កែសំរួលសេចក្តីបកស្រាយ នៃកិច្ចព្រមព្រៀងអឺរ៉ុបពាក់ព័ន្ធការដឹកជញ្ជូនទំនិញគ្រោះថ្នាក់តាមផ្លូវថ្នល់ ដែលអនុវត្តពីថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ២០០១ ។

ង- " ប្រតិបត្តិករដឹកជញ្ជូនឆ្លងកាត់ " មានអត្ថន័យដូចដែលបានកំណត់ក្នុងពិធីសារទី ៣ ស្តីពីប្រភេទ និងបរិមាណយានយន្តតាមផ្លូវគោក អនុលោមទៅតាមកិច្ចព្រមព្រៀង ។

## មាត្រាទី ២
## វិសាលភាពនៃការអនុវត្តន៍

អនុលោមទៅតាមប្រការទី ២០ នៃកិច្ចព្រមព្រៀង, ភាគីចុះកិច្ចសន្យានៅទីនេះយល់ព្រមធ្វើតាមទៅលើប្រការ ដែលមានចែងក្នុងពិធីសារនេះ លើការធ្វើចលនាទំនិញគ្រោះថ្នាក់ទាំងឡាយ ក្នុងការដឹកជញ្ជូនឆ្លងកាត់ តាមផ្លូវថ្នល់ ( ឬ ផ្លូវហាយវេយរវាងរដ្ឋ ) ដែលបានកំណត់ថាជាផ្លូវដឹកជញ្ជូនឆ្លងកាត់ ដូចមានបញ្ជាក់ក្នុងពិធីសារទី ១ នៃកិច្ចព្រមព្រៀង ។

## មាត្រាទី ៣
## ការចាត់ថ្នាក់នូវទំនិញគ្រោះថ្នាក់

ទំនិញគ្រោះថ្នាក់ទាំងឡាយ ត្រូវបានគេបែងចែកទៅតាមចំណាត់ថ្នាក់ ឬផ្នែកដូចខាងក្រោម :

ចំណាត់ថ្នាក់ទី ១ : គ្រឿងផ្ទុះ ( Explosives )

ចំណាត់ថ្នាក់ទី ២ : ផ្នែកទី ២-១ : ឧស្ម័នអាចឆេះ ( Flammable Gases )

ផ្នែកទី ២-២ : ឧស្ម័នដែលមិនអាចឆេះ-មិនមានជាតិពុល (Non-flammable, Non-toxic gases )

ផ្នែកទី ២-៣ : ឧស្ម័នពុល ( Toxic gases)

ចំណាត់ថ្នាក់ទី ៣ : វត្ថុរាវអាចឆេះ និងវត្ថុរាវដែលងាយនឹងផ្ទុះ ( Flammable Liquids and desensitized explosives )

ចំណាត់ថ្នាក់ទី ៤ : ផ្នែកទី ៤-១ : វត្ថុរឹងអាចឆេះ, សារធាតុរិទ្យសកម្មនិងវត្ថុធាតុរឹងដែលងាយបង្កឱ្យផ្ទុះ ( Flammable Solids self-reactive substances and solid desensitized explosive)

ផ្នែកទី ៤-២ : សារធាតុដែលអាចមានចំហេះដោយឯកឯង ( Substances liable to spontaneous combustion )

ផ្នែកទី ៤-៣ : សារធាតុទាំងឡាយដែលមានប្រតិកម្មជាមួយទឹកអាចបញ្ចេញឧស្ម័នឆេះ ( Substances which in contact with water emit flammable gases )